សហភាពអឺរ៉ុប ស៊ុយអែត Sverige

API BUILDING CAPACITY FOR CHANGE

តម្លាភាពកម្ពុជា TRANSPARENCY INTERNATIONAL Cambodia

# របាយការណ៍វាយតម្លៃស្តីពី៖
# ការត្រួតពិនិត្យនូវក្របខណ្ឌច្បាប់ និងការអនុវត្តជាក់ស្តែង
# ចំពោះតម្លាភាពនៃលទ្ធកម្មសាធារណៈ
# នៅព្រះរាជាណាចក្រកម្ពុជា

ការិយាល័យមេធាវី សិង្ហាល័យ

ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២

# មាតិកា


១. សេចក្តីផ្តើម

២. ការវាយតម្លៃ និងអនុសាសន៍

២.១. តម្លាភាព

២.២. ការគ្រប់គ្រងល្អ

២.៣. គណនេយ្យភាព និងសុចរិតភាព

២.៤. ការគ្រប់គ្រង និងការត្រួតពិនិត្យ

២.៥. សិទ្ធិទទួលបានដំណោះស្រាយ

២.៦.ការចូលរួមពីសាធារណៈជន

២.៧. ការបើកចំហ និងការរួមបញ្ចូល

៣. ឯកសារយោង

# ១. សេចក្តីផ្តើម

# ១. សេចក្តីផ្តើម

**លទ្ធកម្មសាធារណៈ៖** គឺជានីតិវិធីនៃការកំណត់នូវអ្វីដែលជាតម្រូវការ កំណត់នូវបុគ្គល ឬអង្គភាពណាដែលជាជម្រើសល្អបំផុតសម្រាប់ផ្គត់ផ្គង់តម្រូវការនេះ និងធានាបានថា តម្រូវការត្រូវបានផ្តល់ឱ្យចំគោលដៅ ទាន់ពេលវេលា ក្នុងតម្លៃសមរម្យ ហើយទាំងអស់នេះត្រូវបានធ្វើឡើងដោយបើកចំហ និងដោយមានភាពយុត្តិធម៌។

# ១. សេចក្តីផ្តើម

## លទ្ធកម្មសាធារណៈនៅកម្ពុជា៖

→ **ច្បាប់កំពុងអនុវត្ត៖** ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ប្រកាសអោយប្រើថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២

→ **កម្មវត្ថុនៃលទ្ធកម្ម៖** ទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា។

→ **វិធីសាស្រ្តនៃការធ្វើលទ្ធកម្ម៖**

- ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ៖ ១) នៅក្នុងស្រុក និង ២) នៅក្រៅស្រុក ។
- លទ្ធកម្មដោយឡែក៖ ១) ការចុះកិច្ចសន្យាដោយផ្ទាល់ ២) ការបន្តចុះកិច្ចសន្យា ៣) ការចុះកិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ និង ៤) ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍។
- ការប្រកួតប្រជែងដេញថ្លៃផ្សេងទៀត៖ ១) ការដេញថ្លៃមានកម្រិត ២) ការពិគ្រោះថ្លៃ និង ៣) ការស្នងតម្លៃ។

→ **ដំណាក់កាលនៃការធ្វើលទ្ធកម្ម៖** ១) មុនពេលដេញថ្លៃ ២) អំឡុងពេលដេញថ្លៃ ៣) ក្រោយពេលដេញថ្លៃ។

# ១. សេចក្តីផ្តើម

## លទ្ធកម្មសាធារណៈនៅកម្ពុជា (បន្ត)៖

- **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៨ ដល់ ២០២៥៖**
  - ការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈ លើកលែងតែកិច្ចលទ្ធកម្មមួយចំនួន ដើម្បីការសន្សំសំចៃ
  - ការពង្រឹងដំណើរការលទ្ធកម្មសាធារណៈអោយមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា និងសៀវភៅណែនាំ
  - ការធ្វើសុខដុមនីយកម្មនីតិវិធីលទ្ធកម្មសាធារណៈជាមួយវដ្តនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- **ច្បាប់កំពុងព្រាង៖** សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (សេចក្តីព្រាងលើកទីមួយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២)

# ២. ការវាយតម្លៃ និងអនុសាសន៍

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | | អនុសាសន៍ |
|---|---|---|---|
| ២.១ តម្លាភាព | ក. ព័ត៌មានជាសាធារណៈ | មិនមានការកំណត់ក្នុងច្បាប់ទាក់ទងនឹងការផ្សព្វផ្សាយនៃនីតិវិធីក្នុងការចរចារ និងលទ្ធកម្មប្រភពតែមួយ | សេចក្តីព្រាងច្បាប់ ស្តីពីលទ្ធកម្មសាធារណៈគួរបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការផ្សព្វផ្សាយនូវនីតិវិធីទាំងនេះ |
| | | កង្វះនូវច្បាប់ទាក់ទងនឹងគោលការណ៍នៃការផ្តល់ថេរវេលាសមស្រប | រាជរដ្ឋាភិបាល គួរអនុម័តនូវច្បាប់ ដែលផ្តល់នូវថេរវេលាជាក់លាក់សម្រាប់៖<br>1) ការផ្សព្វផ្សាយនូវលិខិតអញ្ជើញចូលរួមដេញថ្លៃ និង<br>2) បញ្ញត្តិពាក់ព័ន្ធជាមួយនឹងការឆ្លើយតប ឬ កិច្ចប្រជុំបំភ្លឺ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | | អនុសាសន៍ |
|---|---|---|---|
| ២.១ តម្លាភាព | ខ. ថ្នាល់អនឡាញសម្រាប់លទ្ធកម្មសាធារណៈ | បច្ចុប្បន្នពុំមាននៅកម្ពុជា | សម្រាប់គោលបំណងនៃតម្លាភាព ក៏ដូចជាក្នុងគោលបំណងដើម្បីផ្តល់ជូនព័ត៌មានទាក់ទងនឹងកិច្ចលទ្ធកម្មសាធារណៈដល់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ រាជរដ្ឋាភិបាលគួរតែបង្កើតថ្នាល់អេឡិចត្រូនិចសម្រាប់បង្ហាញនូវព័ត៌មានមិនសម្ងាត់ ទាក់ទងនឹងដំណើរការនៃលទ្ធកម្មសាធារណៈទាំងមូល។ |

# ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | | អនុសាសន៍ |
|---|---|---|---|
| ២.១ តម្លាភាព | ខ. ការពន្យល់ចំពោះសេចក្តីសម្រេច | • ច្បាប់ និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈពុំបានកំណត់អំពីលក្ខខណ្ឌតម្រូវអោយមានការផ្សព្វផ្សាយអំពីការចុះកិច្ចសន្យាលទ្ធកម្ម<br>• ពុំមានលក្ខខណ្ឌណាមួយតម្រូវអោយមានការផ្តល់មូលហេតុទៅកាន់អ្នកដេញថ្លៃដែលពុំទទួលបានជោគជ័យ | • ដំណើរការលទ្ធកម្មទាំងមូល គួរតែមានតម្លាភាព។ ដំណើរការនេះក៏រួមបញ្ចូលទាំងកិច្ចសន្យាដែលបានចុះហត្ថលេខារវាងស្ថាប័នអនុវត្តលទ្ធកម្ម និងអ្នកដេញថ្លៃបានជោគជ័យ។<br>• អ្នកដេញថ្លៃពុំទទួលបានជោគជ័យគួរតែទទួលបាននូវការផ្តល់នូវមូលហេតុពីគណៈកម្មាធិការលទ្ធកម្ម។ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.២ ការគ្រប់គ្រងល្អ | 1. បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាក់ទងនឹងគម្រោងលទ្ធកម្មដែលកំពុងអនុវត្ត | បញ្ហានេះអាចត្រូវបានដោះស្រាយតាមរយៈការដាក់អោយអនុវត្តដោយពេញលេញនូវ៖<br>1) ក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម,<br>2) ការធ្វើសង្គតិភាពថវិកាមូលធន និងថវិកាចរន្ត, និង<br>3) ការធ្វើសង្គតិភាពរវាងលទ្ធកម្មសាធារណៈជាមួយការគ្រោងថវិកា ការអនុវត្តថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ |
| | ២. ហានិភ័យនៃការជះឥទ្ធិពលហួសហេតុលើគណៈកម្មាធិការលទ្ធកម្ម ដោយសារកង្វះខាតយន្តការការពារ | ១) ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដែលផ្តល់កិច្ចការពារដល់គណៈកម្មាធិការលទ្ធកម្ម។<br>២) រាជរដ្ឋាភិបាល គួរតែអនុម័តច្បាប់ និងដាក់ចេញនូវយន្តការដាក់លាក់មួយសម្រាប់ផ្តល់ការការពារដល់គណៈកម្មាធិការលទ្ធកម្ម។ |

# ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៣ គណនេយ្យភាព និងសុចរិតភាព | ១. សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានកំណត់ការប្រកួតប្រជែងជាសាធារណៈជាវិធីសាស្រ្តលទ្ធកម្មសម្រាប់ជ្រើសរើស (Preferred Method) | គួរកែមកជាវិធីសាស្រ្តស្ម័យជម្រើស |
| | ២. ពុំមានបញ្ញត្តិពាក់ព័ន្ធនឹងលទ្ធភាពរបស់ភ្នាក់ងារលទ្ធកម្មក្នុងការធ្វើជាភ្នាក់ងារស្នូលក្នុងកិច្ចលទ្ធកម្ម | ចាំបាច់ក្នុងការពិចារណាបញ្ញត្តិអំពីលទ្ធភាពនេះ និងដាក់បញ្ចូលនូវបញ្ញត្តិដែលកំណត់អំពីសមត្ថកិច្ចជាក់លាក់ |
| | ៣. កង្វះខាតក្របខណ្ឌជាក់លាក់ ពាក់ព័ន្ធនឹងការបោះបង់ចោលកិច្ចលទ្ធកម្ម | ដាក់បញ្ចូលនូវបទប្បញ្ញត្តិដែលផ្តល់លទ្ធភាពក្នុងការបោះបង់កិច្ចលទ្ធកម្ម ដែលរួមបញ្ចូលទាំងការតម្រូវអោយធ្វើការកត់ត្រាអំពីមូលហេតុនៃការបោះបង់ |

# ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
| --- | --- | --- |
| ២.៣ គណនេយ្យភាព និងសុចរិតភាព (បន្ត) | ៤. ពុំមានកាតព្វកិច្ចក្នុងការផ្សព្វផ្សាយអំពីការចុះកិច្ចសន្យាលទ្ធកម្ម | កំណត់កាតព្វកិច្ចក្នុងការផ្សព្វផ្សាយអំពីការចុះកិច្ចសន្យាលទ្ធកម្ម ព្រមទាំងព័ត៌មានច្បាស់លាស់អំពីកិច្ចសន្យានោះ |
| | ៥. ពុំមានការតម្រូវអោយមានការកត់ត្រាទុកនូវសេចក្តីសម្រេចរបស់អង្គភាពលទ្ធកម្ម ឬ ក.ស.ហ.វ. | កំណត់ជាគោលការណ៍តម្រូវអោយមានការកត់ត្រាអំពីការសម្រេចសេចក្តី ដើម្បីអោយមានការតាមដាននីតិវិធីនៃការសម្រេចសេចក្តី |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៤ ការគ្រប់គ្រងនិងការត្រួតពិនិត្យ | ១. ពុំមានប្រកាសស្តីពីនីតិវិធីនៃការបង្កើត គណៈកម្មាធិការសម្រាប់ការប្រគល់ និងការទទួលយក (ទំនិញ និងការងារ) | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាំបាច់កំណត់ប្រកាសនេះ។ |
| | ២. ពុំមានការវិនិច្ឆ័យលើហានិភ័យជាប្រចាំ | រាជរដ្ឋាភិបាលគួរដាក់ចេញនូវវិធានការ ដែលតម្រូវអោយស្ថាប័នគ្រប់គ្រងលទ្ធកម្ម និងអង្គភាពអនុវត្តលទ្ធកម្ម កំណត់នូវហានិភ័យនៃភាពមិនប្រក្រតី និងអំពើពុករលួយដែលអាចកើតមាន នៅក្នុងលទ្ធកម្មសាធារណៈ ដែលត្រូវធ្វើឡើងជាប្រចាំ។ |

# ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៤ ការគ្រប់គ្រង និងការត្រួតពិនិត្យ (បន្ត) | ៤. ការការពារផ្លូវច្បាប់សម្រាប់បុគ្គលរាយការណ៍ | • យន្តការសម្រាប់ការរាយការណ៍ ចាំបាច់ត្រូវតែបង្កើតឡើង សម្រាប់អោយមន្ត្រីពាក់ព័ន្ធរាយការណ៍ពីភាពមិនប្រក្រតីណាមួយទាក់ទងនឹងគម្រោងលទ្ធកម្ម<br>• ចាំបាច់ដាក់ចេញនូវប្រព័ន្ធការពារសុវត្ថិភាពដើម្បីផ្តល់ការការពារដល់មន្ត្រី និង<br>• មន្ត្រីគួរតែទទួលបានការបណ្តុះបណ្តាលលើសុចរិតភាព និងត្រូវបានលើកទឹកចិត្តអោយរាយការណ៍ពីភាពមិនប្រក្រតីណាមួយនៅក្នុងដំណើរការលទ្ធកម្ម។ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៥ សិទ្ធិទទួលបានដំណោះស្រាយ | ១. ពុំមានយន្តការអនុញ្ញាតអោយតតិយជនដែលមានផលប្រយោជន៍ធ្វើការតវ៉ាចំពោះភាពមិនប្រក្រតីក្នុងដំណើរការលទ្ធកម្មសាធារណៈ | គួរពិចារណាដាក់ចេញនូវយន្តការ ដើម្បីដោះស្រាយបញ្ហាកង្វះខាតការផ្តល់សំណងផ្នែករដ្ឋបាល និង/ឬផ្នែកច្បាប់ចំពោះតតិយជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងបញ្ហាដែលត្រូវបានតវ៉ា ដូចជាជម្រើសវិធីសាស្រ្តដេញថ្លៃ។ |
| | ២. ការប្រើប្រាស់ពាក្យមិនច្បាស់លាស់ ក្នុងមាត្រា ៥១ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ទាក់ទងនឹងការតវ៉ាលើសេចក្តីសម្រេចរបស់គណៈកម្មាធិការលទ្ធកម្មចំពោះការសម្រេចប្រគល់កិច្ចសន្យាលទ្ធកម្ម | គួរកំណត់នូវរបបមួយច្បាស់លាស់លើអានុភាពនៃការតវ៉ា ដែលរួមបញ្ចូលទាំងការតវ៉ាដែលបានធ្វើឡើងក្នុងអំឡុងពេលជាប់គាំង។ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៥ សិទ្ធិទទួលបានដំណោះស្រាយ (បន្ត) | ៣. ទំហំនៃសិទ្ធិរបស់ភាគីក្នុងជម្រើសនៃការដោះស្រាយវិវាទ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរកំណត់ទំហំនៃសិទ្ធិនៃភាគីទៅនឹងកិច្ចសន្យាលទ្ធកម្ម ដែលពាក់ព័ន្ធនឹងលទ្ធភាពក្នុងការជ្រើសរើសមជ្ឈតកម្ម ឬយន្តការផ្សេងទៀត សម្រាប់ការដោះស្រាយវិវាទ។ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៦ ការចូលរួមជាសាធារណៈ | ១. ការចូលរួមពីសាធារណៈជន ក្នុងអំឡុងពេលការកែប្រែប្រព័ន្ធលទ្ធកម្មសាធារណៈ | រាជរដ្ឋាភិបាល គួរតែបន្តកោះអញ្ជើញភាគីដែលពាក់ព័ន្ធ ក្នុងការផ្តល់ជាមតិយោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ និងធានាបានថាមតិយោបល់ដែលបានផ្តល់ ត្រូវបានយកមកពិចារណា និងកែប្រែតាមប្រសិនបើសមស្រប។ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៦ ការចូលរួមជាសាធារណៈ (បន្ត) | ២. កង្វះខាតនូវការចូលរួមជាសាធារណៈ និងភាគីដែលពាក់ព័ន្ធ នៅដំណាក់កាលមុនដេញថ្លៃ | សម្រាប់គោលបំណងនៃការចូលរួមដែលមានប្រសិទ្ធភាពនៅពេលការសំណើដេញថ្លៃ រាជរដ្ឋាភិបាល គួរតែរៀបចំការសន្ទនាដោយតម្លាភាព និងទៀងទាត់ជាមួយភាគីពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នភាពអំពីទីផ្សារ និងអនុញ្ញាតអោយបុគ្គលពាក់ព័ន្ធដែលអាចជាអ្នកដេញថ្លៃទទួលបានព័ត៌មានអំពីគោលបំណងនៃគម្រោងលទ្ធកម្មសាធារណៈ។ |

# ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៦ ការចូលរួមជាសាធារណៈ (បន្ត) | ៣. ការមិនបានចូលរួមពីប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ | រាជរដ្ឋាភិបាលគួរតែ៖<br>1) ភ្ជាប់សេចក្តីសង្ខេបអំពីគម្រោងលទ្ធកម្មសាធារណៈជាមួយនឹងឯកសារថវិកាទៅសភា ដើម្បីពិនិត្យ<br>2) ផ្សព្វផ្សាយរបាយការណ៍សង្ខេបអំពីការគ្រោង និងការអនុវត្តកិច្ចលទ្ធកម្មនានា ព្រមទាំងគម្រោងលទ្ធកម្មអាចនឹងមាន<br>3) បើកអោយមានការចូលរួមពីសាធារណៈជនក្នុងនីតិវិធីនៃការដេញថ្លៃ ក៏ដូចជានីតិវិធីនៃការរៀបចំថវិកាសម្រាប់ចំណាយលើកិច្ចលទ្ធកម្មសាធារណៈ។ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| ២.៧ ការបើកចំហរ និងបរិយាបន្ន | ១. កង្វះខាតយន្តការ សម្រាប់ដើម្បីជម្រុញអោយមានចូលរួមពីសំណាក់អ្នកដេញថ្លៃអន្តរជាតិ | រាជរដ្ឋាភិបាល អាចពិចារណាលុបចោលនូវលក្ខខណ្ឌក្នុងការចុះបញ្ជីជាមួយ ក.ស.ហ.វ. ដើម្បីទទួលបានលក្ខណៈសម្បត្តិក្នុងការចូលរួមគម្រោងលទ្ធកម្មសាធារណៈចំពោះដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ |
| | ២. កង្វះខាតនៃការរួមបញ្ចូលយន្តការដែលអនុគ្រោះដល់ការចូលរួមពីសំណាក់សហគ្រាសធនតូចនិងមធ្យម | គួរពិចារណា លើការបញ្ចូលនូវបទប្បញ្ញត្តិដែលអនុគ្រោះដល់ការចូលរួមពីសំណាក់សហគ្រាសធនតូចនិងមធ្យម |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
|---|---|---|
| **២.៧ ការបើកចំហរ និងបរិយាបន្ន (បន្ត)** | ៣. កង្វះខាតនៃនីតិវិធីដែលមានលក្ខណៈស្តង់ដា សម្រាប់ការប្រើប្រាស់វិធីសាស្ត្រ «ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍» ដ៏មានប្រសិទ្ធិភាព | រាជរដ្ឋាភិបាលគួរដាក់បញ្ចូលនូវវដ្តនៃលទ្ធកម្មសាធារណៈឱ្យស្របជាមួយនឹងគោលនយោបាយសេដ្ឋកិច្ចសង្គម។ ឧទាហរណ៍៖<br>➢ គោលការណ៍«លទ្ធកម្មប្រកបដោយចីរភាព» ក្រោមមាត្រា ៥៤ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មគួរតែកែ ដោយដាក់បន្ថែមនូវការពិចារណាលើផលប៉ះពាល់បរិស្ថានជាលក្ខខណ្ឌមួយក្នុងការជ្រើសរើសសំណើដេញថ្លៃ។ ឬ<br>➢ បទប្បញ្ញត្តិអនុវត្តអាចកំណត់នូវលក្ខខណ្ឌនេះ ប៉ុន្តែការកំណត់នេះនឹងមានអានុភាពតិចជាងការកំណត់រួចជាស្រេចនៅក្នុងច្បាប់។ |

## ២. ការវាយតម្លៃ និងអនុសាសន៍

| កម្មវត្ថុ | ចំណុចបញ្ហា | អនុសាសន៍ |
| --- | --- | --- |
| ២.៧ ការបើកចំហ និងបរិយាបន្ន (បន្ត) | ៤. – | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរពិចារណាផងដែរអំពីការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈ លើកលែងតែកិច្ចលទ្ធកម្មដែលតម្រូវអោយមានអំណាចចរចាច្រើន ក្នុងគោលបំណងធានាការទិញដែលមានប្រសិទ្ធិភាព។ បន្ថែមពីនេះ គួរកំណត់អោយមាននូវការទទួលខុសត្រូវចំពោះសង្គមនៅកម្រិតថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការចូលរួមពីសាធារណៈជន។ |

# ៣. ឯកសារយោង

## ឯកសារយោង

| ល.រ | ច្បាប់ |
|---|---|
| ១. | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (សេចក្តីព្រាងលើកទី១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២) ផ្តល់ដោយAPI |
| ២. | ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ |
| ៣. | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ |
| ៤. | ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ |
| ៥. | ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ |
| ៦. | ច្បាប់ស្តីពីសម្បទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ |
| ល.រ | អនុក្រឹត្យ |
| ១. | អនុក្រឹត្យស្តីលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ |
| ២. | អនុក្រឹត្យស្តីលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម |
| ៣. | អនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីបែបបទ និងនីតិវីធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម |
| ៤. | អនុក្រឹត្យលេខ១៨១ អនក្រ.បក ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសំរាប់ការគ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ |

# ឯកសារយោង

| No. | ប្រកាស |
| --- | --- |
| 1. | ប្រកាសលេខ០៤៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ |
| 2. | ប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត រៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| 3. | ប្រកាសលេខ១៨៤៤ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម |
| 4. | ប្រកាសលេខ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា |
| 5. | ប្រកាសលេខ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា |
| 6. | ប្រកាសលេខ៩៨៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីក្រមសីលធម៌លទ្ធកម្ម |
| 7. | ប្រកាសលេខ៩៨៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ណែនាំស្តីពីការត្រួតពិនិត្យលទ្ធកម្មតាមក្រោយ |
| 8. | ប្រកាសលេខ៩៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម |
| 9. | ប្រកាសលេខ១៦១៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការចុះជម្រះ និងការផ្សព្វផ្សាយបញ្ជីខ្មៅ |
| 10. | ប្រកាសលេខ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ |
| 11. | ប្រកាសលេខ០១០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ស្តីពីកម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ |

# ឯកសារយោង

| No. | សារាចរណែនាំ |
|---|---|
| 1. | សារាចរណែនាំលេខ០០១ សហវ.អលសា ចុះថ្ងៃទី២៣ ខែកុម្ភៈឆ្នាំ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ |
| 2. | សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីអនុវត្តលទ្ធកម្មសាធារណៈ |
| 3. | សារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា |
| 4. | សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| 5. | សារាចរណែនាំលេខ០១៥ សហវ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរឹបអូសប្រាក់កក់ក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ |
| 6. | សារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ |
| 7. | សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃ និងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ |
| 8. | សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ |
| 9. | សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ |

# ឯកសារយោង

| No. | សេចក្តីណែនាំ |
|---|---|
| 1. | សេចក្តីណែនាំលេខ០១៤ សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ស្តីពីនីតិវិធីធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ |
| | **នីតិវិធីរួមសម្រាប់ការគ្រប់គ្រង** |
| 1. | Standard Operation Procedure on Procurement for All Externally Financed Projects/Programs in Cambodia, Volume I, 22 July 2020 |
| 2. | Standard Operation Procedure on Procurement for All Externally Financed Projects/Programs in Cambodia, Volume II, 05 October 2020 |
| **No.** | **សៀវភៅ និងឯកសារ** |
| 1. | Asia Development Bank, ADB Procurement Policy: Goods, Works, and Non-consulting and Consulting Services, 2017 |
| 2. | OECD, OECD Recommendation of the Council on Public Procurement, 2015 |
| 3. | OECD, Compendium of Good Practices for Integrity in Public Procurement, 2014 |
| 6. | United Nations, Guide to Enactment of the UNCITRAL Model Law on Public Procurement, 2012 |
| 7. | United Nations Office on Drugs and Crime, Guidebook on Anti-Corruption in Public Procurement and the Management of Public Finances: Good Practices in Ensuring Compliance with Article 9 of the United Nations Convention Against Corruption, 2013 |

# ឯកសារយោង

| No. | ច្បាប់នៃប្រទេសសមាជិកអាស៊ាន |
|---|---|
| 1. | Indonesia Presidential Regulation on Government Procurement promulgated on 22 March 2018 |
| 2. | Government Procurement Act 1997 of Singapore |

| No. | ច្បាប់នៃប្រទេសដទៃ |
|---|---|
| 1. | Directive 2007/66/EC of the European Parliament and of the Council of 11 December 2007 amending Council Directives 89/665/EEC and 92/13/EEC with regard to improving the effectiveness of review procedures concerning the award of public contracts, OJ L 335, 20.12.2007 |
| 2. | Public Procurement Law of Turkey dated January 2012 |

| No. | ឯកសារអន្តរជាតិ |
|---|---|
| 1. | United Nations, UNCITRAL Model Law on Public Procurement dated 2011 |

# សូមអរគុណ